**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

## សារលិខិតជូនពរ

**សូមគោរពជូន**
**ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឃាម ឃឿន អនុប្រធានទី១ នៃរដ្ឋសភា**

**ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំសកល ឆ្នាំ២០២៣ ខាងមុខនេះ ខ្ញុំបាទនិងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់នៃក្រសួងមុខងារសាធារណៈ សូមលើកហត្ថប្រណមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក និងទេវតារក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថែរក្សា ប្រោះព្រំ ប្រទានពរជ័យ សិរីសួស្តី បវរមហាប្រសើរជូន **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត និងលោកជំទាវ**។

ក្នុងឱកាសដ៏មហាប្រសើរថ្លៃថ្លានេះដែរ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវមនោសញ្ចេតនាគោរព និងដឹងគុណដោយស្មោះអស់ពីដួងចិត្តចំពោះទឹកចិត្តដ៏ថ្លៃថ្លា និងសកម្មភាពដ៏ឧត្តុង្គឧត្តមរបស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** ក្នុងបេសកកម្មចូលរួមដឹកនាំស្ថាប័នរដ្ឋសភាជាតិ ដើម្បីបន្តលើកកម្ពស់នីតិរដ្ឋ រក្សាការពារសុខសន្តិភាព ស្ថិរភាពនយោបាយ វិបុលភាព និងការអភិវឌ្ឍលើគ្រប់វិស័យទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅចូលរួមជាឧត្តមប្រយោជន៍ជាតិ និងប្រជាជនកម្ពុជាទូទាំងប្រទេស។

ឆ្លៀតក្នុងឱកាសដ៏រីករាយនិងថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមប្រោសប្រទានជូន **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត និងលោកជំទាវ** ព្រមទាំង **បុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមមានសុខភាពល្អបរិបូរណ៍ និងទទួលបានព្រះពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត អនុប្រធានទី១ នៃរដ្ឋសភា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ និងជ្រាលជ្រៅបំផុតពីយើងខ្ញុំទាំងអស់គ្នា៕

ថ្ងៃចន្ទ ១១រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០២២
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ព្រុំ សុខា